ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...១៧០៤...សហវ.ប្រក

# ប្រកាស
## ស្តីពី
## យន្តការពន្ធដារសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែ សម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៨ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ១០៥៩ ប្រក.សហវ.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់នូវយន្តការពន្ធដារសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់និងអភិវឌ្ឍន៍វិស័យភតិសន្យាហិរញ្ញវត្ថុ។

### ប្រការ ២.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តលើរាល់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដែលធ្វើឡើងដោយភតិបតីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ៣.- និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "ភតិសន្យាហិរញ្ញវត្ថុ (Financial Lease)" សំដៅដល់ភតិសន្យាដែលភតិបតី (Lessor) ចុះកិច្ចព្រមព្រៀងជាមួយភតិក: (Lessee) ដែលក្នុងនោះភតិក:ត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់និងប្រើប្រាស់ចលនវត្ថុក្នុងរយ:ពេលមួយមានកំណត់ ដោយបង់ថ្លៃឈ្នួលចលនវត្ថុតាមគ្រា ឬតាមតម្លៃសមមូល។ ក្នុងប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ភតិបតីគឺជាម្ចាស់កម្មសិទ្ធិនៃចលនវត្ថុ ហើយនៅពេលកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវបានបញ្ចប់ ចលនវត្ថុអាចត្រូវបានទិញផ្តាច់ដោយភតិក:ឬប្រគល់ឱ្យភតិបតីវិញ។

២- ពាក្យ "ភតិបតី" សំដៅដល់បុគ្គលដែលមានការអនុញ្ញាតឬមានអាជ្ញាបណ្ណអាជីវកម្មភតិសន្យាហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា ដែលផ្ទេរសិទ្ធិកាន់កាប់និងសិទ្ធិប្រើប្រាស់ចលនវត្ថុទៅឱ្យភតិក:។ ភតិបតីត្រូវតែជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវបានចាត់ទុកជាស្ថាប័នសញ្ជ័យធនក្នុងស្រុក ដែលមិនត្រូវរងពន្ធកាត់ទុកតាមមាត្រា ២៥ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

៣- ពាក្យ "ភតិក:" សំដៅដល់បុគ្គលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬរបបម៉ៅការ ឬរូបវន្តបុគ្គល ដែលទទួលសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុពីភតិបតី។

៤- ពាក្យ "អ្នកផ្គត់ផ្គង់" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលនិវាសជនដែលផ្គត់ផ្គង់ចលនវត្ថុឱ្យភតិបតីដើម្បីជួលឱ្យភតិក:។

៥- ពាក្យ "ចលនវត្ថុ" សំដៅដល់ទ្រព្យសម្បត្តិ គ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែដីនិងអគារ។

៦- ពាក្យ "តម្លៃចលនវត្ថុ" សំដៅដល់តម្លៃសុទ្ធបន្ទាប់ពីការបញ្ចុះតម្លៃដែលអ្នកផ្គត់ផ្គង់លក់ទៅឱ្យភតិបតី ប៉ុន្តែមិនរួមបញ្ចូលថ្លៃដើមហិរញ្ញវត្ថុ និងចំណាយផ្សេងៗរបស់ភតិបតីទេ។

### ប្រការ ៤.- លក្ខខណ្ឌនៃប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ

សម្រាប់គោលដៅនៃពន្ធដារ លក្ខខណ្ឌនៃភតិសន្យាមានដូចខាងក្រោម÷

ក- ភតិក: ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ដោយមិនផ្អែកសំខាន់លើជំនាញនិងការវិនិច្ឆ័យរបស់ភតិបតីឡើយ

ខ- ភតិបតី ត្រូវទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុដើម្បីជួលឱ្យភតិក:

គ- រយ:ពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុត្រូវចាប់ពីមួយឆ្នាំឡើងទៅ

ឃ- ទឹកប្រាក់សរុបនៃភតិសន្យា ដែលភតិក:ត្រូវបង់ជូនភតិបតី ត្រូវលើសពី ៧៥ ភាគរយ នៃតម្លៃចលនវត្ថុ រួមបញ្ចូលទាំងប្រាក់កក់ និងការបង់ប្រាក់មួយផ្អែកមុន (Down Payment)។

**ប្រការ ៥.៊ យន្តការពន្ធដារចំពោះភតិបតី (ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ)**

ក្នុងកិច្ចប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ភតិបតី ត្រូវអនុវត្តដូចខាងក្រោម ÷

១- អាករលើតម្លៃបន្ថែម (**អតប**)

អនុលោមតាមមាត្រា ៤៨ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ គឺជាការផ្គត់ផ្គង់ ជាប់ **អតប**។ ដូចនេះ ភតិបតីត្រូវ÷

ក- បង់ **អតប** លើការផ្គត់ផ្គង់ចលនវត្ថុជូនអ្នកផ្គត់ផ្គង់ ដោយផ្អែកលើតម្លៃដែលបានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ក្នុងករណីអ្នកផ្គត់ផ្គង់ជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ **អតប** ដែលបានបង់ជូនអ្នកផ្គត់ផ្គង់ ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលនិងត្រូវប្រកាសលើលិខិតប្រកាស **អតប** ប្រចាំខែ។ ក្នុងករណីអ្នកផ្គត់ផ្គង់ជាអ្នកជាប់ពន្ធតាមរបបម៉ៅការ អាករលើផលរបរដែលភតិបតីបានបង់ឱ្យអ្នកផ្គត់ផ្គង់មិនត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលទេ។

ខ- នៅពេលទទួលប្រាក់ថ្លៃឈ្នួលចលនវត្ថុ ដែលត្រូវបង់តាមគ្រាពីភតិកៈ ភតិបតីត្រូវចេញវិក្កយបត្រទៅឱ្យភតិកៈតាមចំនួនដែលបានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ។ ក្នុងវិក្កយបត្រ **អតប** ភតិបតីត្រូវវាយលម្អិតដូចខាងក្រោម÷

ខ.១. ថ្លៃដើមចលនវត្ថុតាមគ្រា ដែលត្រូវជាប់ **អតប** តាមអត្រា ១០ ភាគរយ

ខ.២. បន្ទុកផ្សេងៗដែលត្រូវបង់ដោយភតិកៈ ជាអាទិ៍មាន កម្រៃមេធាវី កម្រៃសេវាភតិសន្យា កម្រៃឯកសារ កម្រៃសេវាដឹកជញ្ជូន... ដែលត្រូវជាប់ **អតប** តាមអត្រា ១០ ភាគរយ

ខ.៣. ការប្រាក់ ដែលមិនត្រូវជាប់ **អតប**។

ក្នុងការចេញវិក្កយបត្រ ភតិបតីត្រូវចេញវិក្កយបត្រ **អតប** (Tax Invoice) ប្រសិនបើភតិកៈជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬវិក្កយបត្រធម្មតា (Commercial Invoice) ប្រសិនបើភតិកៈជាអ្នកជាប់ពន្ធតាមរបបម៉ៅការ ឬរូបវន្តបុគ្គល។

២-ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមា

ថ្លៃដើមចលនវត្ថុតាមគ្រា ក្នុងចំណុច ខ.១ នៃកថាខណ្ឌ ខ នៃប្រការនេះ មិនមែនជាផលរបរសម្រាប់គិតប្រាក់រំដោះពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមាទេ រីឯបន្ទុកផ្សេងៗ និងការប្រាក់ ក្នុងចំណុច ខ.២ និង ខ.៣ នៃកថាខណ្ឌ ខ នៃប្រការនេះ ទើបជាផលរបរសម្រាប់គិតប្រាក់រំដោះពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមា។

៣- ពន្ធលើប្រាក់ចំណេញ

សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណេញ ប្រាក់ចំណូលជាប់ពន្ធរបស់ភតិបតីកើតមានឡើងនាកាលបរិច្ឆេទមុនគេក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់ ឬកាលបរិច្ឆេទដែលបានទទួលការទូទាត់។

**ប្រការ ៦.៊ យន្តការពន្ធដារចំពោះភតិកៈ**

ក្នុងប្រតិបត្តិការអាជីវកម្ម ក្នុងករណីដែលភតិកៈជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសនិងបានចុះបញ្ជីជាបុគ្គលជាប់អាករ ភតិកៈត្រូវអនុវត្តដូចខាងក្រោម ÷

១- កត់ត្រាទឹកប្រាក់ថ្លៃចលនវត្ថុតាមគ្រា បន្ទុកផ្សេងៗ និងការប្រាក់ ព្រមទាំង **អតប** ដែលមានចែងក្នុងវិក្កយបត្រ **អតប** នៃការផ្គត់ផ្គង់ចលនវត្ថុដែលចេញដោយភតិបតីក្នុងសៀវភៅទិនានុប្បវត្តិទិញប្រចាំខែ។

២- មិនអនុវត្តពន្ធកាត់ទុកដូចមានចែងក្នុងមាត្រា ២៥ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ លើថ្លៃឈ្នួលចលនវត្ថុតាមគ្រា និងចំណែកការប្រាក់ដែលបានកត់ត្រាក្នុងវិក្កយបត្រ។

៣- ធ្វើរំលស់នូវតម្លៃគ្មាន **អតប** នៃថ្លៃដើមចលនវត្ថុ ដូចមានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុតាមមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីសារពើពន្ធ ដោយហេតុថាភតិកៈជាអ្នកទទួលខុសត្រូវលើហានិភ័យចំពោះការបាត់បង់ឬខូចខាតនៃចលនវត្ថុ។

ក្នុងករណីកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវបានបញ្ចប់ហើយចលនវត្ថុត្រូវបានទិញផ្ដាច់ដោយភតិកៈ តម្លៃគ្មាន **អតប** នៃចលនវត្ថុដែលបានទិញផ្ដាច់ត្រូវបូកបញ្ចូលទៅក្នុងគណនីរំលស់របស់ចលនវត្ថុដើម្បីធ្វើរំលស់បន្ត។

ក្នុងករណីកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវបានបញ្ចប់ ហើយចលនវត្ថុត្រូវបានប្រគល់ឱ្យភតិបតីវិញ តម្លៃនៅសល់មិនទាន់រំលស់អស់នៃចលនវត្ថុ ត្រូវបានចាត់ជាចំណាយកាត់កងបាន។

**ប្រការ ៧.- ភតិសន្យាហិរញ្ញវត្ថុដែលត្រូវបានរំលាយមុនកាលកំណត់**

ក្នុងករណីកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមិនទាន់ត្រូវបានបញ្ចប់ ហើយចលនវត្ថុត្រូវបានរឹបអូសដោយភតិបតី យន្តការពន្ធដារត្រូវបានអនុវត្តដូចខាងក្រោម÷

១- ភតិបតី ត្រូវ÷

ក- បញ្ចូលចលនវត្ថុក្នុងសន្និធិនៃចលនវត្ថុដែលបានរឹបអូសនូវចំនួនលម្អៀងរវាងថ្លៃដើមគោលនៃចលនវត្ថុ និងថ្លៃដើមគោលសរុបដែលភតិកៈបានបង់

ខ- ក្នុងករណីចលនវត្ថុរឹបអូសត្រូវបានលក់ ភតិបតីត្រូវអនុវត្តតាមវិធាននៃការផ្គត់ផ្គង់ជាប់អាករនៃទំនិញដែលត្រូវជាប់ពន្ធអាករនានាតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន

គ- ក្នុងករណីចលនវត្ថុរឹបអូសត្រូវបានយកមកធ្វើភតិសន្យាហិរញ្ញវត្ថុសាជាថ្មី ភតិបតីត្រូវវាយតម្លៃចលនវត្ថុឡើងវិញក្នុងនោះ÷

គ.១. ចំនួនលម្អៀងត្រូវបានចាត់ទុកជាចំណូលជាប់ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំជាប់ពន្ធចរន្ត ប្រសិនបើតម្លៃថ្មីនៃចលនវត្ថុលើសពីតម្លៃចលនវត្ថុរឹបអូស

គ.២. ចំនួនលម្អៀងត្រូវបានចាត់ទុកជាចំណាយអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធចរន្ត ប្រសិនបើតម្លៃថ្មីនៃចលនវត្ថុ តិចជាងតម្លៃចលនវត្ថុរឹបអូស

ឃ- លុបចោលតម្លៃភតិសន្យាហិរញ្ញវត្ថុត្រូវទទួលក្នុងគណនីភតិសន្យាហិរញ្ញវត្ថុត្រូវទទួល

ង- លុបចោលតម្លៃការប្រាក់ត្រូវទទួលក្នុងគណនីការប្រាក់ត្រូវទទួល

ច- កត់ត្រាជាចំណូលនូវប្រាក់ចំណូលផ្សេងៗនិងពិន័យ ចំពោះភតិកៈអំពីការមិនអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ។

ជ- ក្នុងករណី ភតិបតីយកចលនវត្ថុត្រូវបានរឹបអូស ប្រើប្រាស់ជាទ្រព្យសកម្មរយៈពេលវែង ភតិបតីត្រូវបូកបញ្ចូលទៅក្នុងទ្រព្យសកម្មរយៈពេលវែងតាមថ្នាក់នីមួយៗ តាមតម្លៃនៅសល់មិនទាន់រំលស់ និងអនុវត្តការធ្វើរំលស់តាមកថាខណ្ឌ១ នៃមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីសារពើពន្ធ។

២- ក្នុងករណីដែលភតិកៈ ជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសនិងបានចុះបញ្ជីជាបុគ្គលជាប់អាករ ភតិកៈត្រូវ÷

ក- លុបចោលតម្លៃភតិសន្យាហិរញ្ញវត្ថុត្រូវសងក្នុងគណនីភតិសន្យាហិរញ្ញវត្ថុត្រូវសង

ខ- លុបចោលតម្លៃការប្រាក់ត្រូវសងក្នុងគណនីការប្រាក់ត្រូវសង

គ- លុបចោលតម្លៃពិតគណនេយ្យរបស់ចលនវត្ថុភតិសន្យាហិរញ្ញវត្ថុ

ឃ- ប្រាក់ចំណាយផ្សេងៗនិងពិន័យដែលកំណត់ដោយភតិបតី ចំពោះការមិនអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយ

ង- ចំពោះវិលស់ដែលបានធ្វើក្នុងរយៈពេលអនុវត្តកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវ÷

ង.១. ចាត់ទុកជាចំណាយក្នុងឆ្នាំជាប់ពន្ធ នូវចំនួនលម្អៀងនៃទឹកប្រាក់សរុបដែលបានវិលស់នឹងទឹកប្រាក់សរុបដែលបានបង់ឱ្យភតិបតី ប្រសិនបើទឹកប្រាក់ដែលបានវិលស់តិចជាងទឹកប្រាក់សរុបដែលបានបង់ឱ្យភតិបតី។

ង.២. ចាត់ទុកជាចំណូលក្នុងឆ្នាំជាប់ពន្ធ នូវចំនួនលម្អៀងនៃទឹកប្រាក់សរុបដែលបានវិលស់នឹងទឹកប្រាក់សរុបដែលបានបង់ឱ្យភតិបតី ប្រសិនបើទឹកប្រាក់ដែលបានវិលស់ច្រើនជាងទឹកប្រាក់សរុបដែលបានបង់ឱ្យភតិបតី។

**ប្រការ ៨.- កាតព្វកិច្ចពន្ធដារដទៃទៀត**

គ្រប់ភាគីនៃភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តកាតព្វកិច្ចពន្ធដារដទៃទៀត ដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារជាធរមាន។

**ប្រការ ៩.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ